ISSN 1810-6358

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

**Cambodia Development Resource Institute**

# របាយការណ៍ថ្មីៗស្តីពីសេដ្ឋកិច្ចកម្ពុជា

# Flash Report on the Cambodian Economy

មេសា ២០០៦ / April 2006

**កញ្ញា អ៊ុច ច័ន្ទតារានី / Ms. Ouch Chandarany**

**លោកស្រី ប៉ុន ដូរីណា / Ms. Pon Dorina**

**លោក ហ៊ីង វុត្ថា / Mr. Hing Vutha**

**លោក ភីម រុនស៊ីណារិទ្ធិ / Mr. Phim Runsinarith**

បកប្រែដោយ: **យូ សិទ្ធីរិទ្ធ និង យេន សុផានី**

**ភ្នំពេញ កម្ពុជា**

**Phnom Penh, Cambodia**

**TO SUBSCRIBE, PLEASE CONTACT:**

*Office Address:* #56, Street 315, Tuol Kork, Phnom Penh, Cambodia, *Postal Address:* CDRI, PO Box 622 Phnom Penh, Cambodia
*Tel:* (855-23) 881-384/881-701/881-916/883-603 *Tel/fax:* (855-23) 880-734 *E-mail:* pubs@cdri.forum.org.kh *Website:* http://www.cdri.org.kh

# សកម្មភាពសេដ្ឋកិច្ចសំខាន់ៗរបស់កម្ពុជា

# Main Economic Activities of Cambodia

នៅត្រីមាសទី៤ ២០០៥ ទុនសរុប ២៧,៣លានដុល្លារ (៩ គំរោង) បាន វិនិយោគក្នុងវិស័យកាត់ដេរ (ប្រហែល ២៣% នៃវិនិយោគសរុបនៅត្រីមាសនេះ) ។ ធៀបនឹងត្រីមាសមុន វិនិយោគក្នុងវិស័យកាត់ដេរ ធ្លាក់ចុះអស់ ៥១,៦% ។ ប៉ុន្តែ វាកើនឡើងទ្វេដងធៀបនឹងត្រីមាសដូចគ្នា ២០០៤ ។

In the fourth quarter of 2005, a total of $27.3 million (nine projects) was invested privately in the garment sector, about 23 percent of total investments in the quarter. Compared to the preceding quarter, investment in the garment sector declined by 51.6 percent. However, it doubled from the same quarter in 2004.

**Fixed Asset Investments Approvals by CDC for Garment Sector**
(US$ million)




*Note: Latest data available are for December 2005.*
*Including expansion project approvals.*
Source: Council for the Development of Cambodia and MEF

នៅខែមករា ២០០៦ មានភ្ញៀវបរទេស ៩៦.៧១២នាក់ មកដល់កម្ពុជាតាមជើងហោះហើរអន្តរជាតិ (កើន ៩,៦% ធៀបនឹងខែមុន រីកើន ១៩,៧% ធៀបនឹងខែមករាឆ្នាំមុន) ។ នៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប ទទួលបានភ្ញៀវចំនួន ៦១.១១១នាក់ រីកើន ២៦,៥% រីឯអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ទទួលបានភ្ញៀវចំនួន ៣៥.៦០១នាក់ រីធ្លាក់ចុះ ១១% ។

The number of foreign visitors entering Cambodia by air in January 2006 was 96,712, an increase of 9.6 percent from the preceding month. Arrivals at Siem Reap International Airport rose by 26.5 percent to 61,111 persons, while arrivals at Phnom Penh International Airport declined by 11 percent to 35,601. Compared to January last year, the number of foreign visitors arriving by air increased 19.7 percent. There were increases at both Siem Reap and Phnom Penh airports during this period.

**Foreign Visitor Arrivals by International Flights**
(thousand persons)




*Note: Latest data available are for January 2006.*
Source: Ministry of Tourism

តំលៃគំរោងសាងសង់ដែលបានអនុម័តនៅខែមករា ២០០៦ ធ្លាក់ចុះអស់ ៣៣,៧% ធៀបនឹងខែមុន ដល់ ១៣,៩លានដុល្លារ ។ សំណង់ផ្ទះល្វែង និងភូមិគ្រឹះ បានធ្លាក់ចុះ ៨២,៦% ដល់ ២,៥លានដុល្លារ ហើយគំរោងសាងសង់ផ្ទះ បានធ្លាក់ចុះ ៥៨,២% មកត្រឹមជាង ១លានដុល្លារ ។ រីឯ សំណង់ឯទៀតកើនឡើងជាងពីរដង ដល់ ១០,៤លានដុល្លារ ។ ប៉ុន្តែ តំលៃគំរោងសាងសង់សរុប បានធ្លាក់ចុះអស់ ៦,៣% បើធៀបនឹងខែមករា ឆ្នាំ២០០៥ ។

The value of construction projects approved in January 2006 declined by 33.7 percent from the previous month to $13.9 million. Flat and villa construction decreased by 82.6 percent to $2.5 million, and house construction by 58.2 percent to slightly over $1 million. Meanwhile, other construction activities more than doubled to $10.4 million. However, the total value of construction projects fell by 6.3 percent compared to January 2005.

**Value of Construction Project Approvals in Phnom Penh** (US$ million)




*Note: Latest data available are for January 2006.*
Source: Department of Cadastre and Geography, Phnom Penh Municipality

# អត្រាការប្រាក់ និង ថ្លៃទំនិញ

# Price and Interest Rate Developments

នៅខែមិនា ២០០៦ ថ្លៃប្រេងសាំង និងម៉ាស៊ូតនៅភ្នំពេញ ថយចុះធៀបនឹងខែមុន ។ ថ្លៃសាំងគឺ ៣.៧៥០រៀល/លីត្រ នៅខែមិនា (០,៥%ទាបជាងខែកុម្ភៈ) ។ ដូចគ្នាដែរ ថ្លៃម៉ាស៊ូតធ្លាក់ចុះអស់ ០,៦% ដល់ ២.៨៥៨,៣ រៀល/លីត្រ ។ ប៉ុន្តែ ថ្លៃប្រេងសាំង និងម៉ាស៊ូត នៅតែខ្ពស់ជាងថ្លៃនៅខែមិនា ឆ្នាំ២០០៥ ពោលគឺឡើងថ្លៃ ២០% និង ១៨,៤% រៀងគ្នា ។

Gasoline and diesel prices in Phnom Penh declined in March. The price of gasoline was 3,750 riels/litre in March, 0.5 percent lower than in February. Similarly, the price of diesel dropped by 0.6 percent to 2,858.3 riels/litre. Still, these prices were higher than in March 2005 by 20 percent and 18.4 percent, respectively.

**Price of Gasoline and Diesel Oil in Phnom Penh**
(Riels per litre)




Sources: CDRI and National Institute of Statistics

នៅខែកុម្ភៈ ថ្លៃទំនិញប្រើប្រាស់ទូទៅនៅភ្នំពេញ ធ្លាក់ចុះប្រហែល ០,១% ធៀបនឹងខែមករា ។ សន្ទស្សន៍ថ្លៃទំនិញសំខាន់ៗភាគច្រើន មានការធ្លាក់ចុះ ។ ក្នុងនោះ ថ្លៃម្ហូបអាហារធ្លាក់ចុះអស់ ០,៥% ហើយថ្លៃដឹកជញ្ជូន និងទូរគមនាគមន៍ ធ្លាក់ចុះជាង ០,១% ។

In February, overall consumer prices in Phnom Penh fell by about 0.1 percent from January. The price index of most major items declined. The price of food fell by 0.5 percent, and the cost of transportation and communication was down by slightly over 0.1 percent.

**Consumer Price Index**
(July–December 2000=100)




*Note: Latest data available are for February 2006.*
Source: National Institute of Statistics

យោងតាមធនាគារជាតិនៃកម្ពុជា នៅខែធ្នូ ២០០៥ អត្រាការលើកំចិរយៈ ១២ខែ នៅធនាគារពាណិជ្ជកម្មបរទេសនៃកម្ពុជា គឺ ៥% សំរាប់ប្រាក់បញ្ញើជាដុល្លារUS និង៦,៥% សំរាប់ប្រាក់រៀល (ដូចអត្រានៅខែធ្នូ ២០០៤) ។ ពីខែធ្នូ ២០០៤-ខែធ្នូ ២០០៥ អត្រាការប្រាក់នៅធនាគារកាណាឌីយ៉ា នៅថេរ ៥% សំរាប់ប្រាក់បញ្ញើជាដុល្លារUS និង ៦% សំរាប់ប្រាក់រៀល ។

According to the National Bank, the interest rate on 12-month deposits with the Foreign Trade Bank of Cambodia in December 2005 was 5 percent on US dollar deposits and 6.5 percent on riel deposits, the same as in December 2004. The rate at Canadia Bank also remained stable over December 2004–December 2005, at 5 percent for US dollar deposits and 6 percent for riel deposits. However, ACLEDA Bank provided a higher rate on deposits in riels in December 2005 (8 percent) compared with 6.5 percent in December 2004, while its rate on dollar deposits remained unchanged at 6 percent.

**Interest Rates on 12-Month Deposits**
(As of December 2005)




Source: National Bank of Cambodia

# ស្ថានភាពអត្រាប្តូរប្រាក់ និង រូបិយវត្ថុ

# Exchange Rate and Monetary Developments

បន្ទាប់ពីមានកំនើន៥ខែជាប់ៗគ្នា ប្រាក់រៀលកម្ពុជា បានធ្លាក់ថ្លៃទល់នឹងដុល្លារUS នៅខែមិនា ។ ប្រាក់រៀលជាមធ្យមប្តូរបាន ៤.0៩៦រៀល/ដុល្លារ រឺធ្លាក់ថ្លៃ 0,២% បើធៀបនឹងខែកុម្ភៈ ។ ធៀបនឹងខែដូចគ្នា ឆ្នាំ២00៥ ប្រាក់រៀល ក៏ធ្លាក់ថ្លៃប្រហែល ១,៧% ទល់នឹងដុល្លារUS ដែរ ។

After appreciating for five consecutive months, the riel depreciated against the US dollar in March. The riel averaged 4,096 per dollar in March, a depreciation of 0.2 percent compared to February. Compared to the same month in 2005, the riel depreciated by about 1.7 percent against the dollar.

**Riels per US Dollar**




Sources: National Bank of Cambodia and CDRI

នៅខែមិនា ប្រាក់រៀលធ្លាក់ថ្លៃទល់នឹងប្រាក់បាតថៃ ហើយនិងប្រាក់ដុងវៀតណាម បើធៀបនឹងខែមុន ។ ប្រាក់រៀលធ្លាក់ថ្លៃអស់ ១,៦% ដល់ ១0៤,៨រៀល/បាត ទល់នឹងប្រាក់បាតថៃ និង 0,៣% ដល់ ២៥,៤រៀលក្នុង១00ដុង ។ ធៀបនឹងខែមិនា ឆ្នាំមុន ប្រាក់រៀលឡើងថ្លៃ 0,១% ទល់នឹងប្រាក់បាតថៃ ប៉ុន្តែធ្លាក់ថ្លៃអស់ ២,៦% ទល់នឹងប្រាក់ដុងវៀតណាម ។

The riel also depreciated against both the Thai baht and the Vietnamese dong in March. The riel fell by 1.6 percent to 104.8 per baht and by 0.3 percent to 25.4 riels per 100 dong. Compared to March last year, the riel appreciated by 0.1 percent against the Thai baht, while it fell by 2.6 percent against the Vietnamese dong.

**Riels per Thai Baht and 100 Vietnamese Dong**




Source: CDRI

នៅខែមករា ២00៦ រូបិយវត្ថុទូទៅមាន ៥.២៦៥,៨ពាន់លានរៀល រឺកើន ៤,៨% ធៀបនឹងខែមុន ។ បញ្ញើជារូបិយវត្ថុបរទេស កើនបានប្រហែល ៦% ដល់ ៩២៤,៦លានដុល្លារ (៣.៧៧៣,២ពាន់លានរៀល) ។ ប្រាក់រៀលក្រៅធនាគារ ក៏កើនបាន ៥% ដល់ ១.៣៤៤,៦ពាន់លានរៀល រីឯប្រាក់រៀលក្នុងធនាគារ បែរជាធ្លាក់ចុះ ៣,៥% ដល់ ១៤៨ពាន់លានរៀល ។

Liquidity in January 2006 amounted to 5,265.8 billion riels, 4.8 percent more than in the preceding month. Foreign currency deposits increased by about 6 percent to $924.6 million (3,773.2 billion riels). Riels outside banks also rose by 5 percent to 1,344.6 billion riels, while riels in bank deposits decreased by 3.5 percent to about 148 billion riels.

**Liquidity of the Banking System**
(billion riels)




*Note: Latest data available are for January 2006.*
Source: National Bank of Cambodia

# ពាណិជ្ជកម្មក្រៅប្រទេស
# External Trade

នៅត្រីមាសទី៤ ២០០៥ កម្ពុជាមានការនាំចេញសរុប ៦៤៤,៨លានដុល្លារ រឺ ១១,៧% ទាបជាងត្រីមាសមុន ។ ក្នុងចំណោមផលិតផលនាំចេញសំខាន់ៗ សំលៀកបំពាក់ និងអង្ករ បានធ្លាក់ចុះអស់ ១៥,៣% ដល់ ៦០១លានដុល្លារ និងអស់ ៨៤,៥% ដល់ ០,១លានដុល្លារ រៀងគ្នា ។ ធៀបនឹងត្រីមាសទី៤ ២០០៤ ការនាំចេញសរុបកើនបាន ១៨,៣% ។ ការនាំចេញសំលៀកបំពាក់កើនបាន ១៥,៥% ប៉ុន្តែ ការនាំចេញអង្ករ ធ្លាក់ចុះអស់ ៧១,៧% ។

In the fourth quarter of 2005, Cambodia’s total exports amounted to $644.8 million, 11.7 percent less than in the previous quarter. Among the major export products, garments declined by 15.3 percent to $601 million and rice by 84.5 percent to $100,000. Compared to fourth quarter 2004, total exports rose by 18.3 percent. Garment exports grew by 15.5 percent, although rice exports fell by 71.7 percent.

**Cambodia’s Main Exports**
(US$ million)




*Note: Latest data available are for December 2005.*
Source: Customs and Excise Department

នៅត្រីមាសទី៤ ២០០៥ ការនាំចូលបារី ស៊ីម៉ង់ត៍និងដែក បានធ្លាក់ចុះ ធៀបនឹងត្រីមាសទី៣ ។ ការនាំចូលបារី ធ្លាក់ចុះអស់ ១៦,៤% មកត្រឹម ៧៣,៨ពាន់លានរៀល ។ ការនាំចូលស៊ីម៉ង់ត៍និងដែក ធ្លាក់ចុះអស់ ២៦,១% មកត្រឹម ៣៧,៩ពាន់លានរៀល និងអស់ ៤២,៦% មកត្រឹម ១៧,៨ពាន់លានរៀល ។ ធៀបនឹងត្រីមាសទី៤ ២០០៤ ការនាំចូលរបស់ផលិតផលទាំងបីប្រភេទ មានការធ្លាក់ចុះតិចតួច ។

In fourth quarter 2005, imports of cigarettes, cement and steel declined compared to the third quarter. Cigarette imports decreased by 16.4 percent to 73.8 billion riels. Cement imports dropped by 26.1 percent to 37.9 billion riels and steel by 42.6 percent to 17.8 billion riels. Compared to fourth quarter 2004, the import of all three products declined slightly.

**Imports of Cigarettes and Construction Materials**
(billion riels)




*Note: Latest data available are for December 2005.*
*Excluding public sector imports.*
Source: Customs and Excise Department

នៅត្រីមាសទី៤ ២០០៥ ការនាំចូលម៉ាស៊ូតធ្លាក់ចុះ រីឯការនាំចូលប្រេងសាំង មានការកើនឡើង ធៀបនឹងត្រីមាសមុន ។ ការនាំចូលម៉ាស៊ូតមាន ៨៥,២ពាន់លានរៀល នៅត្រីមាសទី៤ រឺ១៣,៥% ទាបជាងត្រីមាសមុន ។ ការនាំចូលប្រេងសាំងមានដល់ ៤៤,៣ពាន់លានរៀល រឺកើន ៨,១% ។ បើធៀបនឹងត្រីមាសទី៤ ២០០៤ ការនាំចូលម៉ាស៊ូត ធ្លាក់ចុះអស់ ៩,៦% រីឯ ការនាំចូលប្រេងសាំងកើនបាន ៤១,២% ។

In the fourth quarter of 2005, imports of diesel decreased from the previous quarter, while imports of gasoline rose. Diesel imports amounted to 85.2 billion riels in the fourth quarter, 13.5 percent less than in the previous quarter. Meanwhile, gasoline imports reached 44.3 billion riels, an increase of 8.1 percent. Compared to fourth quarter 2004, diesel imports were down by 9.6 percent, while gasoline imports rose by 41.2 percent.

**Imports of Petroleum Products**
(billion riels)




*Note: Latest data available are for December 2005.*
*Excluding public sector imports.*
Source: Customs and Excise Department

# ប្រភព និងការប្រើប្រាស់ជំនួយបរទេស

# Sources and Uses of Foreign Assistance

ដៃគូសហប្រតិបត្តការអភិវឌ្ឍន៍អន្តរជាតិរបស់កម្ពុជា បានបើកផ្តល់ថវិកាសរុបប្រហែល ៦.២៦៧លានដុល្លារ នៃជំនួយអភិវឌ្ឍន៍ផ្លូវការ នៅកំឡុងឆ្នាំ ១៩៩២-២០០៥ ។ នៅឆ្នាំ ២០០៤ ការបើកផ្តល់ថវិកាមានប្រហែល ៥៥៥,៤លានដុល្លារ និងនៅឆ្នាំ ២០០៥ មានរបាយការណ៍ថាប្រហែល ៥២៤,៩លានដុល្លារ ។

International development cooperation partners of Cambodia disbursed a total of about $6,267 million of official development assistance during 1992–2005. In 2004, the disbursement was around $555.4 million, and in 2005 it was reported to be $524.9 million.

**External Development Assistance Disbursements: 1992-2005** (US$ million)




** Revised.*
Source: Council for the Development of Cambodia

កំឡុងឆ្នាំ ១៩៩២-២០០៥ ៧៧% នៃថវិកាបើកផ្តល់សរុប (៤.៨៤៣លានដុល្លារ) ជាជំនួយឥតសំណង ហើយនៅសល់ ២៣% (១.៤២៤លានដុល្លារ) ជាកំចី។ នៅឆ្នាំ២០០៤ ជំនួយឥតសំណងសរុបមាន ៣៦៧,២លានដុល្លារ ធៀបនឹង ៣៧០,៧លានដុល្លារ នៅឆ្នាំ២០០៥ ។ កំចីមាន ១៨៨,២លានដុល្លារ នៅឆ្នាំ ២០០៤ និង ១៥៤,២លានដុល្លារ នៅឆ្នាំ ២០០៥ ។

During 1992–2005, 77 percent of total disbursements ($4,843 million) was in the form of grants, while the remaining 23 percent ($1,424 million) was loans. In 2004, a total of $367.2 million was granted, compared with $370.7 million in 2005. Loans amounted to $188.2 million in 2004 and $154.2 million in 2005.

**External Development Assistance Disbursements by Terms of Assistance: 1992–2005**
(US$ million)




Source: Council for the Development of Cambodia

ក្នុងចំណោមថវិកាបើកផ្តល់សរុបនៅកំឡុងឆ្នាំ ១៩៩២-២០០៥ ម្ចាស់ជំនួយទ្វេភាគីផ្តល់ឱ្យ ៣៨% (២.៣៩២,៥លានដុល្លារ) បន្ទាប់មកគឺទីភ្នាក់ងារពហុភាគី (១.៧៧១,៦លានដុល្លារ) ដែលមានទីភ្នាក់ងារនានារបស់សហប្រជាជាតិ និងវិទ្យាស្ថានហិរញ្ញវត្ថុអន្តរជាតិ ។ សហគមន៍អឺរ៉ុបផ្តល់ឱ្យ ១.៥៧៨,៤លានដុល្លារ នៅកំឡុងពេលនេះ (១៩៩២-២០០៥) ហើយអង្គការក្រៅរដ្ឋាភិបាលផ្តល់ឱ្យ ប្រហែល ៥២៤,៦លានដុល្លារ ។

Of total disbursements during 1992–2005, bilateral donors provided 38 percent ($2,392.5 million), followed by multilateral agencies (United Nations agencies and international financial institutions) with $1,771.6 million. The European Union provided $1,578.4 million during this period, and NGOs offered about $524.6 million.

**External Development Assistance Disbursements by Major Donors: 1992–2005**




Source: Council for the Development of Cambodia

# ការអនុវត្តន៍ថវិកាជាតិ

# National Budget Operations

នៅត្រីមាសទី៤ ២០០៥ (គិតត្រឹមខែវិច្ឆិកា) អតិរេកថវិកាចរន្តមានប្រហែល ៩៩ពាន់លានរៀល ធៀបនឹងអតិរេក ៣១,១ពាន់លានរៀល នៅត្រីមាសទី៣ ។ ប៉ុន្តែនៅត្រីមាសទី៤ ២០០៤ ថវិកាចរន្តមានឱនភាពថវិកា ២៣២,៨ពាន់លានរៀល ។

In fourth quarter 2005 (to November), the current budget surplus was around 99 billion riels, compared to a surplus of 31.1 billion riels in the third quarter. In the fourth quarter of 2004, current budget operations showed a deficit of 232.8 billion riels.

**Current Budget Operations**
(billion riels)




** To November 2005.*
Source: *Monthly Bulletin of Statistics* (MEF)

ចំណូលថវិកាចរន្តមានចំនួន ៣៥២ពាន់លានរៀល នៅត្រីមាសទី៤ ២០០៥ (គិតត្រឹមខែវិច្ឆិកា) ធៀបនឹង ៦០៩,៨ពាន់លានរៀល នៅត្រីមាសទី៣ ។ ចំណូលពីពន្ធមានប្រហែល ២៩១ពាន់លានរៀល នៅត្រីមាសទី៤ ធៀបនឹង ៤៣៦,៣ពាន់លានរៀល នៅត្រីមាសទី៣ ។ ផ្នែកនៅសល់ ៦១ពាន់លានរៀល ជាចំណូលមិនមែនពន្ធ ធៀបនឹង ១៧៣,៥ពាន់លានរៀល នៅត្រីមាសទី៣ ។

Current budget revenue amounted to 352 billion riels in fourth quarter 2005 (to November), compared to 609.8 billion riels in the third quarter. Revenue from tax was about 291 billion riels in the fourth quarter, compared to 436.3 billion riels in the third. The remaining 61 billion riels was revenue from non-tax sources, down from 173.5 billion riels.

**Current Budget Revenue**




** To November 2005.*
Source: *Monthly Bulletin of Statistics* (MEF)

ចំណាយថវិកាចរន្តនៅត្រីមាសទី៤ ២០០៥ (គិតត្រឹមខែវិច្ឆិកា) មានដល់ ២៥៣,១ពាន់លានរៀល ធៀបនឹង ៥៧៨,៧ពាន់លានរៀល នៅត្រីមាសទី៣ ។ ក្នុងនោះ ចំណាយលើរដ្ឋបាលស៊ីវិលមាន ១៧៣,៣ពាន់លានរៀល លើសន្តិសុខ និងកិច្ចការពារជាតិមាន ៧១,៤ពាន់លានរៀល និងលើការប្រាក់របស់កំចីមាន ៨,៤ពាន់លានរៀល ។

Current budget spending in fourth quarter 2005 (to November) reached 253.1 billion riels, compared to 578.7 billion riels in the third quarter. Of this, spending for civil administration amounted to 173.3 billion riels, defence and security 71.4 billion riels and interest on loans 8.4 billion riels.

**Current Budget Expenditure**
(billion riels)




** To November 2005.*
Source: *Monthly Bulletin of Statistics* (MEF)

# សកម្មភាពសេដ្ឋកិច្ចនៃបណ្តាប្រទេសជាដៃគូរបស់កម្ពុជា

# Economic Activity of Selected Economic Partners of Cambodia

នៅខែមករា ២០០៦ ការនាំចេញទំនិញរបស់ US និងតំបន់អឺរ៉ូ បានកើនឡើង រីឯការនាំចេញរបស់ជប៉ុន បានធ្លាក់ចុះ ។ ការនាំចេញទំនិញរបស់ US និងតំបន់អឺរ៉ូ កើន ៣% ដូចគ្នា ធៀបនឹងខែមុន ដល់ ៨១,៧២ពាន់លានដុល្លារ និង១៣២,៨៩ពាន់លានដុល្លារ រៀងគ្នា ។ រីឯការនាំចេញទំនិញរបស់ជប៉ុន បានធ្លាក់ចុះ ១៨% មកត្រឹម ៤៣,២១ពាន់លានដុល្លារ ។

In January 2006, goods exports of the US and the Eurozone increased, while goods exports of Japan decreased. US exports rose by 3 percent from the previous month, from $79.02 billion to $81.72 billion. The increase in goods exports was mostly accounted for by increases in industrial supplies and materials and capital goods. Eurozone exports of goods rose by 3 percent from the previous month, from $129.40 billion to $132.89 billion. Japan's goods exports in January declined by 18 percent from the previous month to $43.21 billion.

### Goods Exports by the US, Eurozone and Japan

(US$ billion)




Sources: BEA, Eurostat and OECD

នៅខែមករា ២០០៦ ការនាំចេញទំនិញរបស់កូរ៉េខាងត្បូង បានធ្លាក់ចុះអស់ ៩% ធៀបនឹងខែមុន ដល់ ២៣,២៧ពាន់លានដុល្លា ។ ការនាំចេញទំនិញគ្រប់ប្រភេទ ដូចជា ម៉ាស៊ីននិងឧបករណ៍ដឹកជញ្ជូន ទំនិញឧស្សាហកម្ម ម្ហូបអាហារនិងសត្វរស់ និងរ៉ែប្រេងកាត បានធ្លាក់ចុះ លើកលែងតែភេសជ្ជៈនិងបារី និងវត្ថុធាតុដើម។ (ស្ថិតិការនាំចេញរបស់តៃវ៉ាន់នៅខែមករា មិនទាន់ចេញផ្សាយទេ)

In January, goods exports of South Korea decreased by 9 percent from the previous month to $23.27 billion. Except beverages and tobacco and raw materials, exports of all other commodities—machinery and transport equipment, manufactured goods, food and live animals and mineral fuels—declined. (Taiwan export statistics for January had not been released at time of publication.)

### Goods Exports by South Korea and Taiwan

(US$ billion)




Sources: National statistics departments of respective countries

នៅខែមករា ២០០៦ ម៉ាឡេស៊ីមានអតិរេកពាណិជ្ជកម្ម ២,៤៤ពាន់លានដុល្លារធៀបនឹង ២,៤៩ពាន់លានដុល្លារ នៅខែធ្នូ ២០០៥ ។ ការនាំចេញសរុបនៅខែមករា ធ្លាក់ចុះ ១២% ធៀបនឹងខែមុន ដល់ ១១,៤៧ពាន់លានដុល្លារ ។ រីឯការនាំចូលសរុប ធ្លាក់ចុះ ១៤% ដល់ ៩,០៣ពាន់លានដុល្លារ ។ ការនាំចូលផលិតផលអគ្គិសនីនិងអេឡិចត្រូនិក ប្រេងឆៅ ផលិតផលពីឈើ ឧបករណ៍អុបទិកនិងវិទ្យាសាស្ត្រ ជាតិគីមី និងប្រេងឆា មានការធ្លាក់ចុះ ។

In January 2006, Malaysia recorded a trade surplus of $2.44 billion, compared to $2.49 billion in December 2005. Total exports in January fell by 12 percent compared to the previous month to $11.47 billion. Total imports fell by 14 percent to $9.03 billion. Exports of electrical and electronic products, crude petroleum, wood products, optical and scientific equipment, chemicals and chemical products and palm oil in January 2006 were down from December 2005.

### Malaysia's External Trade

(US$ billion)




Source: Department of Statistics Malaysia

# ស្ថានភាពអតិផរណានៃបណ្ដាប្រទេសជាដៃគូរបស់កម្ពុជា

# Inflation Rates in Selected Economic Partners of Cambodia

អតិផរណានៅតំបន់អឺរ៉ូទាំងមូល កើន ២,៣% នៅខែមករា ឆ្នាំ២០០៦ បន្ទាប់ពីបានធ្លាក់រហូតតាំងពីខែកញ្ញា ឆ្នាំ២០០៥ មក ។ កំណើននេះ បណ្ដាលជាសំខាន់មកពី កំណើនថ្លៃថាមពល ដូចជា ប្រេងឥន្ធនៈ សំរាប់ដុត និងដឹកជញ្ជូន ព្រមជាកំណើនយ៉ាងយូរនៃថ្លៃហ្គាស និងថ្លៃម្ហូបអាហារ ។ កំឡុងពេលដូចគ្នា អត្រាអតិផរណាទំនិញ ប្រើប្រាស់មាន ៤% នៅអាមេរិក និង ០,៥% នៅជប៉ុន ។

The overall Eurozone year-on-year inflation rate edged up to 2.3 percent in January after a continuous decline since September. This increase was mainly due to higher energy costs in the form of an increase in heating and transportation fuels and also a persistent rise in the gas price and higher prices of unprocessed food. During the same period, the consumer inflation rate ran at 4 percent in the US and 0.5 percent in Japan.

**Inflation Rate in the US, Eurozone and Japan**

(percentage change over previous year)




*Note: The latest data available are for January 2006.*
Sources: IMF and the *Economist* (25-31 March 2006)

ថ្លៃទំនិញប្រើប្រាស់នៅហុងកុង កើនបាន ២,៦% នៅខែមករា ២០០៦ ធៀបនឹងមួយឆ្នាំមុន និងកើនជាង ១,៨% ធៀបនឹងខែធ្នូ ២០០៥ ។ កំនើននេះ បណ្ដាលជាសំខាន់មកពីការឡើងថ្លៃជាងមុននៃ កញ្ចប់ខ្សែទស្សនៈកិច្ច ម្ហូបអាហារជាមូលដ្ឋាន ការដឹកជញ្ជូន ការជួលផ្ទះឯកជន និងគ្រឿងអលង្ការ ។ ក្នុងពេលដូចគ្នា អតិផរណាទំនិញប្រើប្រាស់ កើន ១,៩% នៅចិន និង ២,៨% នៅកូរ៉េខាងត្បូង ។

Hong Kong consumer prices were 2.6 percent higher in January 2006 than a year earlier, an increase over the 1.8 percent figure for December 2005. The rise was mainly attributable to larger increases in charges for package tours, basic foodstuffs, transport fares, private housing rentals and jewellery. During the same period, consumer inflation increased to 1.9 percent in China and 2.8 percent in South Korea.

**Inflation Rate in China, Hong Kong and S. Korea**

(percentage change over previous year)




*Note: The latest data available are for January 2006.*
Sources: IMF and the *Economist* (25-31 March 2006)

នៅខែមករា ២០០៦ អតិផរណារបស់សិង្ហបូរី បានកើនដល់ ១,៧% ។ យោងតាមនាយកដ្ឋានស្ថិតិសិង្ហបូរី រឿងនេះ ឆ្លុះបញ្ចាំងជាចំបងពីការឡើងថ្លៃម្ហូបអាហារ ការស្នាក់នៅ ការអប់រំនិងសំភារៈសិក្សា សុខុមាលភាព និងការសំរាកលំហែ ។ រីឯ អត្រាឆ្នាំលើឆ្នាំនៃអតិផរណាទំនិញប្រើប្រាស់ នៅម៉ាឡេស៊ី មានកំរិត ៣,២% និងនៅថៃមានកំនើនបន្តិចដល់ ៥,៩% ។

Singapore’s year-on-year inflation rose to 1.7 percent in January. According to the Department of Statistics of Singapore, this largely reflected more expensive foodstuffs, housing, education and stationery, health care and recreation. Year-on-year consumer inflation stood at 3.2 percent in Malaysia and rose slightly to 5.9 percent in Thailand.

**Inflation Rate in Selected ASEAN Countries**

(percentage change over the previous year)




*Note: The latest data available are for December 2005.*
Sources: IMF and the *Economist* (4-10 February 2006)

# អត្រាប្តូរប្រាក់លើទីផ្សារអន្តរជាតិ

# Exchange Rates in World Markets

នៅខែមិនា ប្រាក់ដុល្លារអាមេរិក ធ្លាក់ថ្លៃទល់នឹងរូបិយវត្ថុសំខាន់ៗ ។ វាប្តូរបាន 0,៨៣អឺរ៉ូ/ដុល្លារ រឺធ្លាក់ថ្លៃ 0,៦% ធៀបនឹងខែមុន និងប្តូរបាន ១១៧,៣យ៉េន/ដុល្លារ ថោកជាងខែមុនដែលប្តូរបានដល់ទៅ ១១៧,៨យ៉េន/ដុល្លារ ។ ដុល្លារធ្លាក់ថ្លៃដោយសារ ធនាគាកណ្តាលអាមេរិកហាក់ដូចចង់បញ្ចប់ការតំឡើងអត្រាការប្រាក់ជាបន្តបន្ទាប់នេះហើយ ពីព្រោះស្ថិតិពាណិជ្ជកម្មអាមេរិកនាពេលថ្មីៗ មានសូវអំណោយផលដល់ប្រាក់ដុល្លារទេ ។

In March, the US dollar lost ground against many currencies. It exchanged for €0.83, a depreciation of 0.6 percent from the previous month. The dollar traded at ¥117.3, down from ¥117.8 a month earlier. The dollar started to dip as the US Federal Reserve's series of increases in interest rates appeared close to ending and because of the recent US trade statistics which might not be so dollar-friendly.

**Euro and Japanese Yen Against the US Dollar**




*Note: Data are up to 23 February 2006.*
Source: Federal Reserve Bank of New York

នៅខែមិនា ២00៦ ប្រាក់វុនកូរ៉េខាងត្បូងធ្លាក់ថ្លៃទល់នឹងប្រាក់ដុល្លារដោយប្តូរបាន ៩៧៤,៦៩វុន/ដុល្លារ ធៀបនឹង ៩៦៩,១៦វុន/ដុល្លារ នៅខែមុន ។ ប្រាក់វុន ធ្លាក់ថ្លៃ ដោយសារការវាយស្មានថា អតិរេកគណនីចរន្តរបស់កូរ៉េខាងត្បូងនឹងមិនអាចសំរេចតាមផែនការ ហើយធនាគារកណ្តាលកូរ៉េខាងត្បូង នឹងលក់ប្រាក់វុនដើម្បីអាចប្រកួតប្រជែងក្នុងការនាំចេញ ។ ក្នុងកំឡុងពេលដូចគ្នា ដុល្លារហុងកុងគ្មានការប្រែប្រួលថ្លៃទល់នឹងដុល្លារ US ដោយប្តូរបាន ៧,៧៦ ដុល្លារហុងកុង/ដុល្លារ US ។

In March, the South Korean won softened against the US dollar, trading at 974.69 per dollar, from 969.16 a month earlier. The won weakened on speculation that South Korea's current-account surplus might fall short of the target and that the South Korean central bank would sell the won to keep exports competitive. During the same period, the Hong Kong dollar was flat against its US counterpart, trading at 7.76 per US dollar.

**South Korean Won and Hong Kong Dollar against US Dollar**




*Note: Data are up to 23 February 2006.*
Source: Federal Reserve Bank of New York

នៅខែមិនា ២00៦ ដុល្លារសឹង្ហបុរី ប្តូរបាន ១,៦២ដុល្លារសឹង្ហបុរី/ដុល្លារUS ។ ប្រាក់បាតថៃ ប្តូរបាន ៣៨,៩៧បាត/ដុល្លារUS ឡើងថ្លៃបន្តិចពីខែមុនដែលប្តូរបាន ៣៩,៣៤បាត/ដុល្លារUS ។ ធនាគារអភិវឌ្ឍន៍អាស៊ី បានជំរុញឱ្យប្រទេសអាស៊ី រៀបចំទប់ទល់នឹងការធ្លាក់ថ្លៃរបស់ដុល្លារUS និងធ្វើឱ្យរូបិយវត្ថុរបស់ពួកគេឡើងថ្លៃព្រមគ្នា នៅក្នុងឱកាសល្អបែបនោះ ។

In March 2006, the Singapore dollar traded at 1.62 against the US dollar, a slight advance for the fourth month in row. The Thai baht traded at 38.97 baht/USD, a slight gain from 39.34 a month earlier. The Asian Development Bank has urged Asian countries to prepare for a possible sharp fall in the US dollar and to allow their currencies to appreciate collectively in the event of such a decline.

**Thai Baht and Singaporean Dollar against US Dollar**




*Note: Data are up to 23 February 2006.*
Source: Federal Reserve Bank of New York

# ស្ថានភាពតំលៃទំនិញលើទីផ្សារអន្តរជាតិ

# Commodity Prices in World Markets

នៅខែកុម្ភៈ ២០០៦ ថ្លៃអង្ករពិភពលោកបានកើនឡើង ដោយសារមានតំរូវការខ្ពស់ ។ សន្ទស្សន៍ថ្លៃអន្តរជាតិ (IPO) បានកើនដល់ ១២៥,២ពិន្ទុ ធៀបនឹង ១១៨ពិន្ទុនៅខែមករា ។ នៅសហរដ្ឋអាមេរិក ថ្លៃនាំចេញបានកើនឡើងបន្ទាប់ពីនៅថេរអស់ពេលយ៉ាងយូរ ដល់ ៣៥៣ដុល្លារ/តោន ធៀបនឹង ៣០៣ដុល្លារ/តោននៅខែមករា ។ ថ្លៃនាំចេញអង្ករនៅថៃ កើន ៤% ដោយសារមានតំរូវការខ្លាំង ។ នៅខែកុម្ភៈ អង្ករថៃ 100%B ថ្លៃ ៣០៧ដុល្លារ/តោន កើនពី ២៩៥ដុល្លារ/តោន នៅខែមករា ។

In February 2006, world rice prices increased due to strong demand. The international prices index (IPO) rose from 118 in January to 125.2. In the United States, the rice export price climbed after a long period of stability from $303 in January to $353 per ton in February. The Thai export price increased by 4 percent due to strong demand. In February, Thai 100% B rice was at US$307 per ton, up from US$295 per ton in January.

**International Prices Index and Export Rice Prices**
(US$/ton FOB)




Source: Osiriz/InfoArroz and InterRice

នៅខែមិនា ថ្លៃសណ្តែកសៀង និងពោតបានធ្លាក់ចុះ ។ សណ្តែកសៀងលក់បាន ២២៨,៧៣ ដុល្លារ/តោន ដែលកាលពីខែកុម្ភៈលក់បានតែ ២៣៥,៧៥ដុល្លារ/តោន ។ រីឯ ថ្លៃពោតបានធ្លាក់ចុះអស់ ២% ពី ១០៧,៥៤ដុល្លារ នៅខែកុម្ភៈ មកត្រឹម១០៥,១៩ដុល្លារ នៅខែមិនា ។ នៅខែកុម្ភៈ ប្រេងឆាឡើងថ្លៃ ៥% ពី ៤២៤ដុល្លារ/តោន ដល់ ៤៤៥ដុល្លារ/តោន ។

In March, the prices of soybeans and maize decreased. Soybeans sold at $228.73 per ton, down from $235.75 per ton in February. The price of maize decreased by 2 percent from $107.54 per ton in February to $105.19. In February, palm oil increased by 5 percent to $445 per ton, up from $424 in January.

**International Prices of Soybean, Maize and Palm Oil** (US$/ton FOB)




Source: Food and Agriculture Organisation

នៅខែមិនា ប្រេងឆៅ និងសាំងបានឡើងថ្លៃ ។ ថ្លៃប្រេងឆៅលក់ដល់ដៃរបស់ប្រទេស OPEC នៅខែមិនា គឺ ៥៧,៦០ដុល្លារ/ធុង រីមានកំណើន ២% ធៀបនឹងខែមុន ។ សាំងធម្មតានៅ US Gulf Coast ឡើងថ្លៃ ១៥% ដល់ ៤៦,៥៩សេន/លីត្រ ធៀបនឹង ៤០,៥៥សេន/លីត្រ នៅខែកុម្ភៈ ។

In March, the prices of crude oil and gasoline increased. The OPEC countries spot price of crude oil was $57.60 per barrel, a 2 percent increase from the previous month. Regular gasoline on the US Gulf Coast rose by 15 percent, selling at 46.59 cents per litre compared to 40.55 cents in February.

**Prices of Crude Oil and Gasoline**




*Note: Data are up to 25 March 2006.*
Source: US Energy Information Administration

# ព័ត៌មានសេដ្ឋកិច្ច

# Economic News

**កិច្ចពិភាក្សាកូរ៉េខាងត្បូង-អាស៊ានស្តីពីតំបន់ពាណិជ្ជកម្មសេរី មានការរីកចំរើនតិចតួច:** កិច្ចពិភាក្សាស្តីពីពាណិជ្ជកម្មសេរីលើកទី១០ រវាងកូរ៉េខាងត្បូង និងសមាជិកអាស៊ានទាំង១០ នៅក្រុងហ្សាកាតា មិនបានកាត់បន្ថយការខ្វែងមតិពីទំហំនៃការកាត់បន្ថយពន្ធគយលើ ផលិតផលអាចប៉ះពាល់ខ្លាំងនោះទេ ។ ក្នុងចំនោមទំនិញ ៥.២០០ប្រភេទ មាន ២០០ប្រភេទ ត្រូវកូរ៉េចាត់ថាអាចប៉ះពាល់ខ្លាំង និងត្រូវដកចេញពីការលើកលែងពន្ធគយភ្លាមៗ ។ កាលពីមុនភាគីទាំងពីរបានយល់ស្របជាគោលការណ៍លើ ៥វិធីខុសៗគ្នាសំរាប់ធ្វើសេរីភាវូបនីយកម្មបណ្តើរៗលើទំនិញប៉ះពាល់ខ្លាំង ប៉ុន្តែ មិនទាន់យល់ស្របគ្នាថាវិធីណាត្រូវប្រើលើផលិតផលណាទេ ។ កិច្ចពិភាក្សាពាណិជ្ជកម្មសេរីលើកចុងក្រោយ នឹងធ្វើឡើងនៅខែមេសា ។

**កូរ៉េខាងត្បូង និងកម្ពុជា ព្រមព្រៀងរឹតចំណងទាក់ទងខាងពាណិជ្ជកម្ម វប្បធម៌ និងទេសចរណ៍:** កូរ៉េខាងត្បូង និងកម្ពុជា ឯកភាពគ្នាបង្កើតគណៈកម្មការរួមមួយដើម្បីរឹតចំណងទាក់ទងខាងពាណិជ្ជកម្ម/ការទូត ធ្វើការផ្លាស់ប្តូរខាងវប្បធម៌/ទេសចរណ៍ និងធ្វើសហប្រតិបត្តិការណ៍ដើម្បីឱ្យកូរ៉េអាចចុះហត្ថលេខាពាណិជ្ជកម្មសេរីបានឆាប់ ជាមួយប្រទេសអាស៊ានទាំង១០ ។

**លទ្ធផលដ៏លេចធ្លោនៃទេសចរណ៍កម្ពុជា:** ក្នុង៣ឆ្នាំចុងក្រោយនេះ ទេសចរណ៍កម្ពុជា បានរីកចំរើនយ៉ាងលឿន ។ បន្ទាប់ពីទទួលភ្ញៀវទេសចរបរទេសបានដល់១លាននាក់ជាលើកដំបូងក្នុងប្រវត្តិសាស្ត្រកម្ពុជានៅឆ្នាំ២០០៤ ភ្ញៀវអន្តរជាតិបានស្ទុះឡើងដល់ ១,៣៥លាននាក់ រឺកើន ២៧,៤% នៅឆ្នាំមុននេះទៀត។ តាំងពីឆ្នាំ២០០១ មក ភ្ញៀវទេសចរមកកម្ពុជា បានកើន ១២៣% ជាលទ្ធផលមួយដ៏ប្រសើរខ្លាំងណាស់ក្នុងចំនោមប្រទេសនៅអាស៊ីអាគ្នេយ៍ ។ ក្រសួងទេសចរណ៍បានព្យាករណ៍ថា នឹងមានភ្ញៀវទេសចរបរទេសពី ១,៥ - ១,៦លាននាក់នៅឆ្នាំនេះ និង២លាននាក់នៅឆ្នាំ២០០៧ ដោយផ្អែកលើកត្តាជាច្រើនដូចជា និតិវិធីសាមញ្ញក្នុងការសុំទិដ្ឋការ កន្លែងត្រួតពិនិត្យព្រំដែនអន្តរជាតិបើកថែមថ្មី និងគោលនយោបាយបើកចំហជើងមេឃ ។

**កម្ពុជា នឹងទទួលបានជំនួយអន្តរជាតិ ៦០១លានដុល្លារ:** ម្ចាស់ជំនួយអន្តរជាតិបានសន្យាផ្តល់ជំនួយអភិវឌ្ឍន៍ ៦០១លានដុល្លារ ដល់កម្ពុជានៅឆ្នាំនេះ ទោះបីមានការបារម្ភថា រដ្ឋាភិបាលបានធ្វើការតិចតួចក្នុងការទប់ស្កាត់អំពើពុករលួយដ៏រាំរ៉ៃនេះ។ ប៉ុន្តែម្ចាស់ជំនួយបានលើកថា ពួកគេមានការលើកទឹកចិត្តពីអ្វីដែលគេហៅថា កាយវិការផ្សះផ្សាររបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ចំពោះគូប្រជែងនយោបាយ។ នៅឆ្នាំ២០០៤ ម្ចាស់ជំនួយអន្តរជាតិបានសន្យាផ្តល់ ៥០៤លានដុល្លារ ជាជំនួយទ្វេភាគី និងពហុភាគី ។ ជំនួយធំបំផុតសំរាប់ឆ្នាំ២០០៦ គឺរបស់សហគមន៍អឺរ៉ុប (១៦៤លានដុល្លារ) និង ជប៉ុន (១១៤,៧លានដុល្លារ)។ អាមេរិកផ្តល់ជំនួយ ៦១លានដុល្លារ សំរាប់គំរោងខាងអប់រំ ថែទាំសុខភាព និងអភិបាលកិច្ចល្អ អនុវត្តដោយស្ថាប័នឯកជននានាដែលធ្វើការនៅកម្ពុជា ។

***South Korea-ASEAN FTA Talks Make Little Headway:*** A tenth round of free-trade negotiations between South Korea and the 10-member ASEAN bloc that ended in Jakarta failed to narrow differences about the extent of tariff reduction on some highly sensitive products. Of 5,200 items, 200 are categorised as highly sensitive by Korea, and to be excluded from immediate tariff exemption. The two sides previously agreed in principle on five different ways to gradually liberalise highly sensitive goods, but failed to agree on how to match approaches with specific products. The next and final round of FTA talks is scheduled for April. *(Cited from Arirange News, 29 March 2006)*

***South Korea, Cambodia agree to tighten business, cultural, tourism ties:*** South Korea and Cambodia agreed to set up a joint committee to tighten their business and diplomatic ties and step up cultural and tourism exchanges, South Korea's presidential office in Seoul said. The two countries also agreed to cooperate to ensure that South Korea can quickly sign a free trade accord with the 10-country Association of Southeast Asian Nations. *(Cited from the China Post, 29 March 2006)*

***Spectacular performance for Cambodia's tourism:*** For the last three years, Cambodian tourism has been growing at a rapid rate. After 1 million international visitors were recorded for the first time in history in 2004, growth gained momentum last year with a jump of 27.4 percent to 1.35 million international visitors. Since 2001, tourism to Cambodia has increased by 123 percent, one of the best results of all countries in south-east Asia. Projections by the Ministry of Tourism point to 1.5 to 1.6 million international visitors this year, and the 2 million mark should be reached by 2007. This very positive forecast is based on a number of factors: simplified visa procedures, new international border checkpoints and a liberal open-skies policy. *(Cited from Travel Daily News, 29 March 2006)*

***Cambodia promised US$601 million in international aid:*** Foreign aid donors have pledged $601 million (€500 million) in development aid for Cambodia this year, despite concerns that the government has done little to curb endemic corruption. The donors said, however, that they were encouraged by what they described as conciliatory gestures made by Prime Minister Hun Sen toward his political opponents. In 2004, international donors pledged US$504 million (€420 million) in bilateral and multilateral contributions. The largest pledge for 2006 was $164 million (€140 million) from the European Union, followed by $114.7 million (€96.2 million) from Japan. The United States pledged $61 million (€51 million) for education, health and good governance projects to be carried out by private groups working in Cambodia. (*Cited from Thestar, 4 March 2006)*